# អ្នកនឹងទទួលបាននូវការជួយគាំទ្រយ៉ាងពិតប្រាកដ នៅពេលដែលអ្នកត្រូវការបំផុត។

មិនថាអ្នក មករកយើងឱ្យជួយក្នុងហេតុផលអ្វីទេ យើងនឹងមានកម្មវិធី ឬ ធនធានផ្សេងៗ ដែលអាចជួយគាំទ្រដល់អ្នក ឱ្យសម្រេចទៅតាមគោលដៅរបស់អ្នកបាន។ យើងនឹងជួយអ្នកឱ្យសម្រេចទៅតាមគោលដៅកំណត់។

## ភាពអត់ការងារធ្វើ

- ផ្តល់ ប្រាក់ចំណូល បណ្តោះអាសន្ន នៅពេលអ្នកបាត់បង់ការងារ ឬនៅពេលដែលអ្នក ត្រូវបានគេ កាត់បន្ថយម៉ោងធ្វើការ ដោយគ្មានកំហុស។
- អ្នកអាចទទួលបានថវិកាចំនួនចន្លោះពី $40 ទៅ $450 ក្នុងមួយសប្តាហ៍ អាស្រ័យលើ ប្រាក់ចំណូល របស់អ្នកក្នុងរយៈពេល 18 ខែកន្លងមក។

**edd.ca.gov/Unemployment**

## ភាពពិការ

- ផ្តល់ប្រាក់ចំណូលបណ្តោះអាសន្ននៅពេលដែលអ្នកមិនអាចធ្វើការបានដោយសារ មានជំងឺ ឬរបួស ការមានផ្ទៃពោះ ឬការសម្រាលកូន។
- អ្នកអាចទទួលបានថវិកាចំនួនចន្លោះពី 70 ទៅ 90 ភាគរយនៃប្រាក់ឈ្នួលប្រចាំសប្តាហ៍ដែលជាប្រាក់ចំណូលរបស់អ្នក កាលពី 5 ទៅ 18ខែ មុនកាលបរិច្ឆេទចាប់ផ្តើមការទាមទារសំណងរបស់អ្នក។

**edd.ca.gov/Disability**

## ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល

- ផ្តល់ការបង់ប្រាក់អត្ថប្រយោជន៍ រហូតដល់ទៅប្រាំបីសប្តាហ៍ ដល់អ្នកដែលត្រូវការ ពេលវេលាសម្រាកពីការងារដើម្បី៖
  - ថែទាំសមាជិកគ្រួសារដែលមានជំងឺធ្ងន់ធ្ងរ។
  - ការបង្កើតភាពស្និទ្ធស្នាល ជាមួយកូនទើបប្រសូត្រ។
  - ចូលរួមក្នុង ព្រឹត្តិការណ៍ដែលមានលក្ខណៈគ្រប់គ្រាន់ ដោយសារតែការដាក់ពង្រាយ យោធា របស់ សមាជិកគ្រួសារ។
- អ្នកអាចទទួលបានថវិកាចំនួនចន្លោះពី 70 ទៅ 90 ភាគរយនៃប្រាក់ឈ្នួលប្រចាំសប្តាហ៍ដែលជាប្រាក់ចំណូលរបស់អ្នក កាលពី 5 ទៅ 18ខែ មុនកាលបរិច្ឆេទចាប់ផ្តើមការទាមទារសំណងរបស់អ្នក។

**edd.ca.gov/PaidFamilyLeave**

## សេវាកម្មការងារ

- ជាផ្នែកមួយនៃប្រព័ន្ធអភិវឌ្ឍន៍កម្លាំងការងាររបស់រដ្ឋ EDD មានវត្តមាននទីនេះ ដើម្បីជួយដល់ អ្នកស្វែងរកការងារ ក្នុងការស្វែងរកឱកាសការងារល្អៗនានា។
  - ស្វែងរកការអប់រំ និង ការបណ្តុះបណ្តាលការងារ។
  - ការស្វែងរកការងារ ការបង្ហឹកអាជីពការងារ ការជួយគាំទ្របន្ត និងជាច្រើនទៀត។
  - ការប្រើប្រាស់បន្ទប់ធនធានក្នុងមូលដ្ឋានជាមួយ អ៊ីនធើណែត ទូរសព្ទ និងអ្វីៗជាច្រើនទៀត។
- ទទួលបានការបញ្ជូនបន្ត ទៅកាន់ សេវាកម្មគាំទ្ររួមមាន ការថែទាំកុមារ ទឹក ភ្លើង ទីលំនៅ និងមធ្យោបាយដឹកជញ្ជូន។

**edd.ca.gov/StrongerCA**

**សិក្សាស្វែងយល់បន្ថែម អំពីជម្រើសនៃការបង់ប្រាក់ អត្ថប្រយោជន៍ នៅ**
**edd.ca.gov/PaymentOptions.**